**សេចក្តីប្រកាសស្តីពីការស្រាវជ្រាវ “ ការសិក្សាស្រាវជ្រាវបែបពិពណ៌នាមួយស្តីអំពីវិសមភាពសុខភាពនៃជម្ងឺមិនឆ្លងក្នុងចំណោមប្រជាជនរស់នៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា”។**

មន្ទីរពេទ្យជប៉ុនសាន់រ៉ាយស៍ភ្នំពេញ នឹងធ្វើការស្រាវជ្រាវដូចបានរៀបរាប់ខាងក្រោម។ ការសិក្សានេះ នឹងត្រូវបានធ្វើឡើងដោយយោងទៅតាមគោលការណ៍ស្តីពីក្រមសីលធម៌ស្រាវជ្រាវដែលពាក់ព័ន្ធបន្ទាប់ពីត្រូវបានត្រួតពិនិត្យ និង ធ្វើការអនុម័តយល់ព្រមដោយគណៈកម្មាធិការជាតិក្រមសីលធម៌ ដើម្បីការស្រាវជ្រាវពីសុខភាព។
រយៈពេលគម្រោង ៖ គិតចាប់ពីថ្ងៃទទួលបានការអនុម័តពីគណៈកម្មាធិការជាតិក្រមសីលធម៌រហូតដល់ខែធ្នូ ឆ្នាំ ២០២១។
**« ចំណងជើងការស្រាវជ្រាវ »**

ការសិក្សាស្រាវជ្រាវបែបពិពណ៌នាមួយស្តីអំពីវិសមភាពសុខភាពនៃជម្ងឺមិនឆ្លងក្នុងចំណោមប្រជាជនរស់នៅក្នុងតំបន់ជនបទនៃប្រទេសកម្ពុជា។
**« គោលបំណង»**
គោលបំណងនៃការស្រាវជ្រាវ គឺដើម្បី កំណត់ស្វែងរកវិសមភាពសុខភាពនៃជម្ងឺមិនឆ្លងក្នុងចំណោមប្រជាពលរដ្ឋរស់នៅជនបទដែលពិបាកក្នុងការទទួលបាននូវសេវាសុខភាពចាំបាច់ ដោយការវិភាគទិន្នន័យនៃការពិនិត្យសុខភាពឥតគិតថ្លៃ។
**«ការវិភាគការស្រាវជ្រាវ»**

យើងធ្វើការវិភាគទិន្នន័យដែលទទួលបាននូវការពិនិត្យសុខភាពវេជ្ជសាស្ត្រដោយឥតគិតថ្លៃនៅខេត្តព្រៃវែងដើម្បីស្វែងរកវិសមភាពសុខភាព និងជំរុញសុខភាពប្រជាជន។ យើងនឹងវិភាគអំពីទំនាក់ទំនងរវាងបុគ្គលិកលក្ខណៈរបស់អ្នកជម្ងឺ និងបញ្ហាសុខភាពរបស់អ្នកជម្ងឺទាក់ទងនឹងជម្ងឺមិនឆ្លង។ ទិន្នន័យនឹងមិនត្រូវបានបញ្ចេញឈ្មោះ និងត្រូវបានរក្សាទុកយ៉ាងសម្ងាត់ នៅមន្ទីរពេទ្យជប៉ុនសាន់រ៉ាយស៍។
**«ឈ្មោះស្ថាប័នស្រាវជ្រាវ»**
មន្ទីរពេទ្យជប៉ុនសាន់រ៉ាយស៍រភ្នំពេញ
សង្កាត់ ជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា
**«ការគ្រប់គ្រងពត៌មានផ្ទាល់ខ្លួន»**
បើអ្នកចង់ដឹងពត៌មានលំអិតអំពីការវិភាគនិងលទ្ធផលនៃការស្រាវជ្រាវ ឬអ្នកមិនត្រូវបាន

អនុញ្ញាត្តិអោយប្រើចំលើយរបស់អ្នកនៃកម្រងសំនួរចំពោះការស្រាវជ្រាវ
សូមធ្វើការទាក់ទងសាកសួរពត័មានដែលបង្ហាញខាងក្រោម។
បើអ្នកមិនត្រូវបានអនុញ្ញាត្តិអោយប្រើទិន្នន័យ
អ្នកនឹងមិនទទួលបានផលប្រយោជន៍ពីវេជ្ជសាស្ត្រឡើយ។

**« អាស័យដ្ឋានទំនាក់ទំនង»**

Yurie Kobashi
មន្ទីរពេទ្យជប៉ុនសាន់រ៉ាយស៍ភ្នំពេញ
អ៊ីមែល ៖ kobashi.yurie@sunrise-hs.com